នួន ឃឿន

# ដំណើរឆ្ពោះទៅទិសខាងលិច

និង

# ឥណ្ឌូចិនក្នុងឆ្នាំ២០០០

[ សាកល្បង ]

ការផ្សាយរបស់អ្នកនិពន្ធ

រក្សាសិទ្ធិ


បោះពុម្ពលើកទី១ ចំនួន ២.០០០ ច្បាប់

តម្កល់ទុកតាមលេខ ១១១២ ចុះថ្ងៃទី ៩វិច្ឆិកា ឆ្នាំ១៩៧០

បោះនៅ ក្រុមហ៊ុនការពុម្ពខ្មែរ

ព.ស. ២៥១៤ គ.ស. ១៩៧០







# អារម្ភកថា

វិភាគទានដ៏វិសេសវិសាលដែលកូនខ្មែរម្នាក់ៗ អាចផ្តល់ចំពោះជាតិមាតុប្រទេសរបស់ខ្លួន ដើម្បីឲ្យជាតិរបស់ខ្លួនគង់វង្សជីវិតក្នុងបណ្តាភូមិភាគមួយដែលប្រកបដោយគ្រោះថ្នាក់នោះ គឺការស្គាល់តម្លៃវប្បធម៌ អារ្យធម៌ និងជាពិសេសប្រវត្តិសាស្ត្រជាតិខ្លួននេះឯង ។

ប្រវត្តិសាស្ត្រកត់ត្រាទុកគ្រប់កំហុស ដែលដូនតាយើងបានប្រព្រឹត្តរួចមកហើយក្នុងអតីតកាល គ្រប់ទាំងភាពថ្កុំថ្កើងរុងរឿងដែលបានធ្វើឲ្យរាស្ត្រប្រជាជាតិខ្មែរ និងវប្បធម៌ខ្មែរ អណ្តែតត្រដែតខ្ពង់ខ្ពស់ ក្នុងពពកនៃពិភពគ្រេះគ្រង ។ អំពើ ឬព្រឹត្តិការណ៍ទាំងនេះនោះជាផ្តល់ដល់ប្រជាជាតិយើង នូវល្បីល្បាញរន្ទឺសុះសាយក្តី ឬក៏ភាពអាម៉ាស់មុខពន់ប្រមាណក្តី ដែលមានចែងនៅលើគ្រប់ទំព័រនៃពង្សាវតារជាតិ ក៏អំពើទាំងឡាយនោះឯងជាកេរ្តិ៍មរតកឥតកាត់តម្លៃបានដែលយើងទទួលអំពីដូនតាយើងមក ។

គឺអំពើ ឬព្រឹត្តិការណ៍ទាំងនេះហើយ ដែលបង្កើតនូវសម្បជញ្ញៈខ្មែរ ។ ជនជាតិខ្មែរសម័យនេះ ជាលទ្ធផលនៃអតីតកាល ឬជាលទ្ធផលនៃសម្បជញ្ញៈខ្មែរនេះឯង ។

ពិតមែនហើយដែលថាក្នុងប្រវត្តិសាស្ត្រ នៃប្រទេសយើង យើងមានឆ្លងកាត់នូវភាពអាម៉ាស់មុខយ៉ាងច្រើន ចាប់តាំងពីសតវត្សទី ១៣ ដល់សម័យបច្ចុប្បន្នកាលនេះ ក្រោយពីបានស្គាល់ភាពរុងរឿង



អស់រយៈពេលដ៏យូរ (ពីសតវត្សទី ៨ មកសតវត្សទី ១៣) ក្តី, តែប្រជាជាតិយើង, ពូជសាសន៍យើង, វប្បធម៌និងអារ្យធម៌យើង មិនបានរលាយសូន្យ បាត់ស្រមោលពីសាកលលោកឡើយ ។ អារ្យធម៌ជាច្រើនក្នុងលោកនេះ ដែលធ្លាប់បានស្គាល់ភាពរុងរឿងត្រចះត្រចង់ក្នុងអតីតកាល ខ្វះត្រូវទទួលវាសនាអាក្រក់ធ្លាក់ចុះទៅក្នុងពិភពងងឹតនៃការភ្លេចភ្លាំងរបស់មនុស្ស ឬ ក៏រលាយបាត់ស្រមោលសូន្យសុងពីសម្បជញ្ញៈមនុស្សជាតិ ដូចមានអារ្យធម៌កាល់ដេ (Chaldée), អាស្ស៊ីរី (Assyrie), ក្រិក (Grèce) ឬ រ៉ូម (Rome) ។ល។

ដូច្នេះ ប្រជាជាតិយើង អារ្យធម៌យើង ដែលបានតស៊ូទប់ទល់នឹងការឈ្លានពានឥតឈប់ឈរអំពីអ្នកជិតខាងឥតសប្បុរសធម៌ តាំងពីជាង ១ សតវត្សរួចមកហើយតែមិនព្រមចុះចាញ់ មិនព្រមទម្លាក់អាវុធចុះញ៉មវាសនាភ័ព្វរបស់ខ្លួននោះ នេះជាវាសនាដ៏ឧត្តុង្គឧត្តមមួយណាស់ហើយ ។ នៅសតវត្សទី១៩, ប្រជាជាតិខ្មែរយើងមានបណ្តាជនមិនបានដល់មួយលាននាក់ផង (ប្រហែលជា ៨០០.០០០ នាក់ បើតាមអស់លោកអ្នកប្រាជ្ញបារាំង ដែលបានមកទស្សនានិងសិក្សាប្រទេសយើងជាលើកដំបូង) សម័យនោះយើងស្មានតែយើងបានស្គាល់ទីបំផុតនៃជីវិតរបស់ប្រជាជាតិយើងរួចទៅហើយ តែយើងបែរជារស់រានមានជីវិតឡើងវិញ ។ ហើយមិនត្រឹមតែរស់ឡើងវិញប៉ុណ្ណោះទេ ថែមទាំងបានរៀនចំរើនយើងអនុលោមទៅតាមសម័យទំនើប វិទ្យាសាស្ត្រទៀតផង ។ ហើយថ្វីការនេះទៀត របបសក្តិភូមិរាជានិយមផ្តាច់

ការដែលជាទម្ងន់ក្ងួយធ្ងន់ពន់ប្រមាណមកលើវាសនាខ្មែរគ្រប់រូប និង ជាប្រភពនៃភាពអោនថយរបស់ប្រជាជាតិយើងនោះទៀត, ឥឡូវ យើងបានរាយកំទេចបំផ្លាញរបបចង្រៃនេះ យកជ័យជំនះជាស្រេចលើ របបនោះរួចទៅហើយ ។

ម្តងនេះ យើងនឹងស្គាល់ជាថ្មីម្តងទៀត នូវពន្លឺនៃសេចក្តីថ្លៃថ្នូរ នៃ សេចក្តីហាន និងសេរីភាព ។ យើងអស់ឧបសគ្គអ្វីមករារាំងក្នុង ដំណើរយើងទៅកាន់ការចាប់កំណើតរស់ឡើងវិញ នៃប្រជាជាតិយើង ទៀតហើយ ។

មួយចំណែកទៀត, ប្រជាជនយើងក្នុងសម័យនេះមានរហូតដល់ ៨ លាននាក់, នោះបើយើងមិនរាប់ខ្មែរនៅយៀកណាមខាងត្បូងនឹង នៅថៃឡង់ ដែលមានចំនួនពី ៣ ទៅ ៤ លានទៀតផង ។ ក្នុង៣០ ឆ្នាំទៀត ប្រជាជននៅក្នុងដែនដីកម្ពុជាសព្វថ្ងៃនេះនឹងកើនទៅដល់១៥ លាននាក់ហើយ ។ បើយ៉ាងដូច្នេះ, តើសត្រូវណា អ្នកជិតខាង ណា ឬ មហាអំណាចណាក្នុងលោកនឹងអាចកាប់សម្លាប់ បំផ្លិច បំផ្លាញជាតិខ្មែរពី ៨ ទៅ ១៥ លាននាក់បានដែរឬ ?

វាសនារបស់ប្រជាជាតិយើងក្នុងអនាគតកាល គឺយើងត្រូវតែរស់ៗ តែត្រង់ចំណុចថារស់បែបណាៗនោះ គឺ "រស់គ្រាន់តែរស់" ឬរស់ ក្នុងសេចក្តីចំរើនក្នុងភាពថ្លៃថ្នូរនោះ នេះជាបញ្ហាមួយទៀតដ៏ធំដែល យើងរាល់គ្នាត្រូវតែគិតដោះស្រាយ ព្រោះបើ "រស់គ្រាន់តែរស់" ដោយ



ក្រហេបក្រហប ស្ទើររស់ស្ទើរស្លាប់ រស់ក្នុងបណ្តាការខ្វះសេចក្តីថ្លៃ ថ្នូរ អយុត្តិធម៌ វេទនាថយថោក... ពុំណោះទេ, នោះស្លាប់ទៅ វាប្រសើរជាង ។ ដើម្បីកុំឲ្យសេចក្តីលំបាកវេទនា ឈឺចាប់ ខ្លោចផ្សា ដែលធ្លាប់មានអស់រយៈជាង ៦ សតវត្សទៅហើយនោះ នេះតែបន្តទៅទៀត ។

ការរៀបចំប្រជាជាតិខ្មែរ រដ្ឋខ្មែរឡើងវិញ ស្របទៅតាមគោល ការណ៍លទ្ធិប្រជាធិបតេយ្យ តាមផ្លូវនយោបាយ ( Démocratie politique) និងតាមផ្លូវសង្គម (Démocratie sociale) គឺជាការចាំ បាច់ជាមូលដ្ឋាន នៃប្រទេសកម្ពុជាសម័យថ្មី ។

អ្នកនិពន្ធនៃសៀវភៅតូចនេះយល់ថា ដរាបណា គំនិតប្រជាធិប តេយ្យ សេរីភាព ស្ថិតនៅតែលើក្រដាស មិនក្លាយទៅជា ការពិតជាក់ស្តែងក្នុងកិច្ចការប្រតិបត្តិ ក្នុងជីវភាពរាល់ថ្ងៃរបស់រាស្ត្រ ខ្មែរគ្រប់រូប ឬនៅតាមភូមិជនបទទេនោះ ដរាបនោះយើងមិនអាច រំដោះជនជាតិខ្មែរ ឬប្រជាជាតិខ្មែរ ពីភាពជាក់ស្បាតតក់ស្លុត ចុះ ញ៉មមុខប្រយុទ្ធ សេចក្តីល្ងង់ខ្លៅ ឬ ការគ្មានជំនឿទៅលើខ្លួនឯង នោះបានឡើយ ។

គ្មានអ្វីពិបាកជាងការផ្លាស់ប្តូរ របោះបង់ចោលគំនិតចាស់មួយដែល មានអាយុរាប់សតវត្សរួចមកហើយនោះទេ ។ តែនេះក៏ មិន មែនកិច្ចមួយដែលគេ មិនអាចសម្រេចបាននោះក៏ទេដែរ ។ សេចក្តី

ក្លាហាន ឬកនិងការប៉ុនប្រសប់របស់អ្នកនយោបាយខ្មែរ ក្នុងក្របខណ្ឌនៃយុទ្ធវិធីមួយ ដែលគម្រូរនឹងចិត្តគំនិតខ្មែរ សង្គមខ្មែរពិតប្រាកដជាការពិបាកណាស់ តែជាការចាំបាច់ជាចម្បងដើម្បីសំរេចនូវបដិវត្តខ្មែរ ។

× × ×

គំនិតដែលលោកអ្នកអាននឹងឃើញក្នុងសៀវភៅតូចនេះ ប្រហែលជាលឿនពេក ឬក៏ហួសពេក ឬមួយក៏អាចបណ្តាលឲ្យមានការស្រងាកចិត្តខ្លះក៏សឹងមាន ។ អ្នកអានខ្លះអាចចោទអ្នកនិពន្ធថា ជាអ្នកមានគំនិតឧត្តមគតិនិយម ។ល ។

អ្នកនិពន្ធ ចំពោះរឿងនេះ ជាខ្មែរម្នាក់ មានកំណើតនៅចម្ងាយ ៦ គីឡូម៉ែត្រពីអង្គរវត្ត បានទទួលការអប់រំមិនឆ្ងាយប៉ុន្មានពីអង្គរវត្ត បានស្គាល់ហើយស្រឡាញ់អង្គរវត្ត ដូចជាទ្រព្យសម្បត្តិរបស់ខ្លួនផ្ទាល់ បានកំពេញវ័យ ចំណោមមហាប្រាង្គសិលា ជាកំណប់នៃវប្បធម៌ អារ្យធម៌ ប្រវត្តិសាស្ត្រខ្មែរ សព្វសឹងជាកេរ្តិ៍មត៌កនៃភាពរុងរឿងសម័យមហានគរ ។ ជាការធម្មតា ការស្គាល់និងការស្រឡាញ់ប្រភពនៃអារ្យធម៌ខ្មែរ និងប្រជាជាតិខ្មែរនេះ ជម្រុញចិត្តឲ្យមានការនឹកស្រណោះដល់អតីតកាល ចង់ឃើញប្រជាជាតិខ្មែរក្លាយទៅជាពិភពមួយរុងរឿងត្រចះត្រចង់ដូចដែលខ្មែរធ្លាប់ស្គាល់ក្នុង អតីតកាលសម័យ "មហានគរ" ដូច្នោះដែរ ។

ក្នុងគំនិតនេះ អ្នកនិពន្ធគ្មានប្រយោជន៍អ្វី នឹងការពារខ្លួនគិត



ណាដែលផ្ទុយនឹងប្រយោជន៍ខ្ពង់ខ្ពស់របស់ជាតិផងខ្លួននោះឡើយ ។

គឺ ពីព្រោះតែជាការមួយដែលទាក់ទងដល់អនាគតជាតិ ដល់អនាគតពូជសម្ពន្ធខ្មែរនេះហើយ ដែលអ្នកនិពន្ធអត្ថបទនេះមិនខ្លាចអ្វីនឹងលោកព្រមាង ទាំគំនិត ឬ យោបល់របស់ខ្លួនដែលជាលទ្ធផលនៃការត្រិះរិះត្រាវជ្រាវរបស់ខ្លួនសុទ្ធសាធ ជូនដល់មតិសាធារណជនជាតិត្រង់ជាការពិចារណា ។ ឯការពិតសច្ចៈនោះស្រេចតែការវិនិច្ឆ័យ យល់ឃើញរបស់មតិសាធារណជនជាតិចុះ ។

អ្នកនិពន្ធសៀវភៅតូចនេះ មានជំនឿយ៉ាងមាំថា ប្រសិនបើការអានសៀវភៅនេះ បណ្តាលឲ្យមានការពិចារណា ធ្វើការវិនិច្ឆ័យមែននោះ នោះគោលដៅបំណងអ្នកនិពន្ធ បានសំរេចហើយ ។ គោលដៅរបស់អ្នកនិពន្ធ គឺលើកយកបញ្ហាអនាគតខ្មែរ យកមកចោទចំពោះសម្បជញ្ញៈខ្មែរ គឺបង្កើតឲ្យមានជាបញ្ហាឡើងដើម្បីគិតកុំឲ្យភ្លេចខ្លួន ក្នុងឋានៈខ្លួនជាខ្មែរ រស់នៅលើដែនដីត្រជាក់ សុវណ្ណភូមិនេះ ។

សូមលោកអ្នកអានមេត្តាអភ័យទោស ប្រសិនបើនៅលើទំព័រទាំងនេះ មានការអធិប្បាយដោយមានលាយតណ្ហាខ្លះ ព្រោះយើងមិនអាចបំភ្លេចឲ្យស្ងួតស្ងៀមនូវទោសកង្វះរបស់យើង ចំពោះការសាងជាតិបានឡើយ ។ គឺជាការធម្មតាទេ ដែលបេះដូងមនុស្សម្នាក់ ស្រពាប់ស្រពោន កាលបើស្រមោលនៃអតីតកាលដែលជាស្រ

មោលនៃការឈឺចាប់របស់ជាតិខ្លួន លេចឡើងមកក្នុងសម្បជញ្ញៈ មនុស្សនេះ ឬកបក្សាលជាមួយនឹងភាពរន្ធត់ញាប់ញ័រនៅចំពោះមុខ អនាគតកាលខ្វះមិនសោ ។

ចំពោះរាស្ត្រខ្មែរក្នុងអនាគត , អ្នកនិពន្ធសៀវភៅតូចនេះ តែងតែចែករំលែកជាមួយផងដែរនូវសេចក្ដីសង្ឃឹម ដែលដូនតាយើងពីព្រេងនាយរមែងបានចិញ្ចឹមទុកក្នុងសន្ដានចិត្តខ្មែរ ។ សេចក្ដីសង្ឃឹម និងជំនឿនេះ ស្ថិតក្នុងពាក្យស្លោក ឬ ពាក្យទំនាយមួយឃ្លា ដែលដូនតាយើងធ្លាប់បានពោលត ៗ គ្នាមកថា : " ស្រុកខ្មែរមិនដែលសូន្យ ! " ( Le Pays Khmer ne périra jamais ! )

ភ្នំពេញ ខែធ្នូ ១៩៧០

ង. ឃ.

«Qu'il soit du Nord ou du Sud, il n'est pas un Vietnamien qui ne se sente solidaire du frère dont on l'a arbitrairement séparé, singulier couronnement de l'indépendance recouvrée alors que le « colonialisme» français avait poursuivi le rêve d'hégémonie de l'empereur Gia-Long et que tout son effort avait tendu vers la mise en commun de richesses inégalement réparties mais complémentaires les unes des autres. Comment nourrir la population du Nord-Vietnam sans les réserves alimentaires du Sud et comment mettre en valeur les terrains du Sud sans l'excédent de main-d'œuvre du Nord ? Pour comprendre le problème, imaginons une ligne de démarcation qui couperait en France le grenier à blé de la Beauce et les paturages normands des houillères du Nord et de la métallurgie de l'Est. Pour une superficie de rizières trois fois moindre, le Tonkin a deux fois plus de bouches à nourrir, mais il détient le charbon, le fer, les matières et les sources d'énergie nécessaires à la grande industrie.

Que l'on n'objecte pas les tendances particularistes du Nord et du Sud, maintes fois relevées au cours de l'histoire. Ce serait oublier que l'Allemagne et l'Italie ont connu les mêmes dissensions intérieures et que leur unification au XIXè siècle a conditionné leur accession au rang de grande puissance.

Le problème se pose dans les mêmes termes pour l'avenir du Vietnam»

André MASSON
in «Histoire du Vietnam»
P.U.F. 1960

# - សេចក្ដីផ្ដើម -

តើប្រទេសវៀតណាម នឹងក្លាយទៅជាប្រទេសអាល្លឺម៉ាញមួយនៅក្នុងតំបន់ភាគអាស៊ីប៉ែកអាគ្នេយ៍ ក្នុងអនាគតឆាប់នេះឬ ?

ក្នុងឋានៈខ្ញុំជាជនជាតិខ្មែរមួយរូប ដែលរស់ស្លាប់នៅលើមាតុភូមិខ្មែរ និងក្នុងឋានៈជាអ្នកសិក្សាប្រវត្តិវិទ្យា ខ្ញុំសូមចងក្រងសៀវភៅនេះ ដល់ការភ្ញាក់រឭកនៃសម្បជញ្ញៈនៃជនជាតិខ្មែរ និងដល់សេចក្ដីចំរើនល្អស្អាត នៃការយោគយល់គ្នារវាងជាតិ និងជាតិ ដែលជាគន្លឹះតែមួយគត់ នៃការរួមរស់ដោយសន្តិភាពក្នុងប៉ែកនេះនៃពិភពលោក ។



តើជនវៀតណាម នឹងក្លាយទៅជាជនជាតិអាល្លឺម៉ង់ក្នុងអាស៊ីភាគអាគ្នេយ៍ ហើយជាពិសេស ចំពោះកម្ពុជាយើងឬ ?

ខ្ញុំពុំអាចនឹងចោទសួរបញ្ហានេះឡើង ដោយហេតុការណ៍ចាប់ភ្លាមៗក្នុងសម្បជញ្ញៈរបស់ខ្ញុំបានឡើយ ។

បទពិសោធន៍ទាំងឡាយនៃស្រវឹងស្រវាំង ស្ដីពីទេ តែនឹងកើតឡើងក្នុងសម្បជញ្ញៈខ្ញុំ កាលណាយើងវាយតម្លៃខ្ញុំពិតជាចង់ដល់បញ្ហាដ៏ធំធេង និងស្មុគស្មាញនេះ ជាពិសេសគឺបញ្ហានៃការគង់វង់ជីវិតរបស់កម្ពុជាយើង ក្នុងឋានៈជាប្រជាជាតិមួយ (Nation) ក្នុងភូមិភាគអាស៊ីប៉ែកអាគ្នេយ៍នេះ ។ ម៉្យាងទៀត, នេះជាបញ្ហានៃអនាគតកាលដែលពិបាក នឹងប្រមើលមើលដោយពិតប្រាកដទុកជាមុន ហើយមួយចំណែកទៀតប្រវត្តិសាស្ត្រអាចមានករណីលើកលែងដែរ.... ។

តែបើទុកជាយ៉ាងដូច្នេះក្ដី យើងអាចត្រិះរិះបានខ្លះពីបញ្ហានេះ ដោយអាងទៅលើលំនាំ នៃប្រវត្តិសាស្ត្រ

មនុស្សជាតិ ក៏ស្គាល់ប្រវត្តិសាស្ត្រ ដែលកន្លងមកហើយ និងហេតុការណ៍ជា សាវតាខ្លះ ៗ ដែលយើងបានឃើញក្នុង ពេលសព្វថ្ងៃក្នុងបច្ចុប្បន្នកាលនេះឯង

### មេរៀននៃប្រវត្តិសាស្ត្រគឺអ្វី ?

យើងពុំមានបំណងយកទំព័រនេះមកបង្រៀនអំពីទស្សនវិជ្ជា នៃប្រវត្តិសាស្ត្រ (Philosophie de l'Histoire) ទេ តែគ្រាន់តែយើង លើកការពិភាក្សាខ្លះ ដែលអាចមានអត្ថប្រយោជន៍ ចំពោះការយល់ របស់យើង យើងត្រូវចៀសវាងឲ្យ ការពោលដោយម៉ឺងម៉ាត់ (le dogmatisme) តែយើងត្រូវតែ ជាអ្នកប្រាកដនិយម ។ មនុស្សជាច្រើនបានចោទសួរចំពោះមេរៀននៃប្រវត្តិសាស្ត្រ នេះថា:

តើប្រវត្តិសាស្ត្រមានមេរៀនផ្ដល់មកឲ្យ យើងទេ ? ឬតើប្រវត្តិសាស្ត្រមានប្រយោជន៍ ទេ ? ។ បើស្របតាមលោក ហ៊ែហ្គែល (Hegel) ប៉ូល វ៉ាឡេរី (Paul Valery) ប្រវត្តិសាស្ត្រអាចមានឬគ្មាន



ប្រយោជន៍អ្វីទាល់តែសោះ ។ ចំពោះយើង យើងយល់ថា ប្រវត្តិសាស្ត្រមានប្រយោជន៍ផង ហើយគ្មានប្រយោជន៍ផង ប្រវត្តិសាស្ត្រដែលគ្មានប្រយោជន៍ ដែលហាក់ដូចជាយ៉ាង នេះគឺ ដោយហេតុថា គ្មានបាតុភូតព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ឯណា (Phènomènes ou évènements historiques) អាចកើត ឡើងវិញពីរដង ហើយមានលក្ខណៈដូចគ្នាឡើយ ( les évènements historiques ne se répètent pas,ou tout du moins de la même façon ) ។

ការពន្យល់នេះ អាស្រ័យដោយហេតុថា ក្នុងសម័យ មួយ មានស្ថានភាពឬលក្ខខណ្ឌ ( Conditions ) សង្គមកិច្ច នយោបាយ វប្បធម៌ សេដ្ឋកិច្ច. . . . ខុសពីសម័យមួយទៀត ដូច្នេះហើយ យើងពុំអាចរកស្ថានភាពពីរ ឲ្យមានលក្ខណៈ ដូចគ្នាបានទេ យ៉ាងណាមិញ យើងក៏ពុំអាចទាញយកមេរៀនអ្វី មួយឲ្យប្រាកដប្រជាអាចយកទៅជាគំរូបានឡើយ ។

ឥឡូវយើងយកឧទាហរណ៍មកពន្យល់ :

សង្គ្រាមលោកលើកទី១ ទុកណាជាទម្លាក់ការខុសត្រូវទៅលើប្រទេសអាល្លឺម៉ង់ក្តី ក៏មូលហេតុដែលបណ្តាលនេះស្មុគស្មាញណាស់ មិនមែនតែប្រទេសអាល្លឺម៉ង់ម្នាក់ឯងទេ គឺទ្វីបអឺរ៉ុបនេះឯងជាអ្នកទទួលខុសត្រូវ, ដោយបណ្តាលឲ្យមានចំការប្រណាំងប្រជែង ( Rivalités ) ខាងផ្លូវសេដ្ឋកិច្ច ឧស្សាហកម្ម ពាណិជ្ជកម្ម, ហើយចុងក្រោយបង្អស់ ការប្រណាំងប្រជែងផ្លូវនយោបាយទូតនិងយោធា ហើយទាំងអស់គឺជាផលវិបាកនៃការលូតលាស់ឡើងវឌ្ឍន៍ នៃរបបមូលធនអន្តរជាតិផង ( développement du capitalisme international ) ។ ដល់សង្គ្រាមលោកលើកទីពីរផ្ទុះឡើង ពិភពលោកហាក់ដូចជាយល់ថា ប្រវត្តិសាស្ត្រថយក្រោយវិញច្រំដែល(se répéter) ។

ប្រទេសអាល្លឺម៉ង់បង្កសង្គ្រាមលោកទៀតហើយ តែលើកនេះការកើតទៅ, សង្គ្រាមលោកលើកទីពីរនេះ គឺបណ្តាលមួយភាគធំមកពីការឆ្កួតលីលា( la folie ) នៃមនុស្សម្នាក់គឺហ៊ីត្លែ ( Hitler ) នេះឯង ។ រីឯស្តេចអាល្លឺម៉ង់វិញពីសម័យ



ហ្គីយោម ទី២ (Gullaume II) មកសម័យហ៊ីត្លែរ គឺមានការប្រែប្រួលច្រើនណាស់ទៅហើយ ។ ឯចំណែកស្ថានការណ៍អន្តរជាតិផ្នែកសេដ្ឋកិច្ចនយោបាយ វិទ្យាសាស្ត្រក៏ដូច្នោះដែរ ។

តើចំណុចនេះឬ ដែលគេសន្និដ្ឋានថា ប្រវត្តិសាស្ត្រគ្មានប្រយោជន៍ ? នេះគឺជាមតិឬជានិក្ខេបបទ ( Thèse )មួយដែរ ។ តែបើយើងពិចារណាឲ្យជ្រៅជ្រះដោយយកចម្ងាយ នៃការវិវត្តន៍នេះជាទីតាំង, យើងពុំអាចកាត់ផ្តាច់ប្រវត្តិសាស្ត្រជាកង់ដុំៗ(Morceaux) ចេញពីគ្នាឡើយ ។ បច្ចុប្បន្នកាលយើងនេះជាលទ្ធផលនៃអតីតកាលថ្មីៗ ហើយអតីតកាលថ្មីៗនេះទៀតក៏ជាលទ្ធផលនៃអតីតកាលសម័យបុរាណ ។ល។ ហើយគេថយទៅក្រោយរហូតទៅដល់កំណើតនៃពិភពលោក... ។ ជាការពិតណាស់ វត្ថុក្នុងលោកនេះ គ្រប់ៗគឺដោយមានការទាក់ទងគ្នាយ៉ាងជិតស្និទ្ធ (Tout est lié à tout) ។ យ៉ាងណាមិញយើងពុំអាចផ្តាច់អតីតកាលថ្មីៗ ឬបុរាណនិងបច្ចុប្បន្នកាល និងអនាគតកាលបានឡើយ ។ ដូច្នេះប្រវត្តិសាស្ត្រប្រាកដជា គន្លឹ

បណ្ដាំមកលើបច្ចុប្បន្នកាលនិងអនាគតកាល ។

គឺក្នុងន័យនេះហើយ ដែលយើងគួរលើកយកបញ្ហាដើមទាស់យើងមកដោះស្រាយនូវបញ្ហា នៃការគង់វង្សជាតិប្រជាជាតិយើងក្នុងបរិការណ៍នៃពិភពលោក, ចំពោះផលប្រយោជន៍យើងទាំងអស់គ្នា ។

x

x x

# ប្រទេសវៀតណាមនិងយើងក្នុងអតីតកាល

ក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ មានចលនាទេសន្តរប្រវេសន៍ (Migration) មួយដែលមានលក្ខណៈជាទូទៅ ហើយយើងគេសង្កេតមានមកហើយ ក្នុងសម័យអតីតកាលឬកាលណានិងថ្មីនេះ គឺ " ដំណើរទៅទិសខាងត្បូង " (La marche vers le sud) នៃជនជាតិទាំងឡាយ ដែលរស់នៅផ្នែកខាងជើងនៃផែនដី (Hémisphère Nord) ។

ដូចនេះនៅទ្វីបអឺរ៉ុបជនខាងជើងដូច នរម៉ង់ (Normands) ហ្សែម៉ានិក ( Germaniques ) បាននាំគ្នាចុះមកខាងក្រោម ចាប់តាំងពីសតវត្សទី៤-៦ រហូតមកដល់សតវត្សទី១១-១២ ។ នៅទ្វីបអាស៊ីជនជាតិ អារ្យ៉ង់ (Aryens) សម្បុរស បានចុះមកពីប៉ែកខាងត្បូងនៃប្រទេស រុស្ស៊ី មកតាំងនៅខាងត្បូងនៃភ្នំ

វាលទំនាប ក្នុងទឹកដីនៃ ទន្លេសិន្ធុ និង ទន្លេគង្គា (Plaine Indo gangetique) ហើយរុញច្រានជាតិ ឥណ្ឌា ដើមសម្បុរខ្មៅ (Les Dravidiens) ឲ្យចុះមកនៅផ្នែកខាងត្បូង (Le Dekkan)

នៅខាងកើត និងខាងលិច នៃប្រទេស កម្ពុជា ជនជាតិសៀម ដែលមានដើមកំណើត នៅក្នុងតំបន់ខេត្ត យូណាន (Yunnan) នៃប្រទេសចិន, បានចាប់ផ្តើមសម្រុកចុះមកខាងត្បូង តាំងពីសតវត្សទី ១៤ មកម្ល៉េះ ដោយបានមកតាំងនៅក្នុងតំបន់ខេត្តខ្មែរទាំងឡាយ ខាងលិចប្រទេសកម្ពុជា សម័យបច្ចុប្បន្ន ហើយរុញច្រាន រហូតដល់នៅ [illegible] រួចតាំងទីនៅលើក្រើនខេត្ត ប៉ាឡាយ នេះផង ។ [illegible] ដែលនេះ ជនជាតិ យៀកណាម ដែលមានដើមកំណើត នៅក្នុងភាគ តុង កឹង (Tonkin) ក៏បានធ្វើការសម្រុកចុះមកក្រោមដែរ មកដល់ ចុងសតវត្សទី ១៦ ជនជាតិយៀកណាម បានកាន់កាប់ដណ្តើមហើយតាំងទី របស់ខ្លួនក្នុងតំបន់ខេត្តខាងជើងទាំងឡាយ នៃនគរ ចាម



(Champa) មានខេត្ត ក្វាងប៊ិញ (Quang Binh) ក្វាងទ្រី (Ouang Tri) ហ្វេ (Hué) ហើយរហូតមកដល់ ទូរ៉ាន (Tourane) សន្សឹម ៗ ពីសតវត្សទី ១៥ មកដល់សតវត្សទី ១៧ នគរ ចាម ទាំងមូល រហូតមកដល់ ប៊ិញធ្វាន់ (Binh thuan) ដែលខាងត្បូងបំផុត ត្រូវរលាយបាត់ឈ្មោះពីផែនទី នៃពិភពលោក (១៦៩៦) ។

ការកាត់ទឹកដីនៅក្នុងនគរចម្ប៉ា មិនទាន់ទាំងចប់ស្រេចបាត់ហើយផង, និងមជន « យួន » ក៏ចាប់ផ្តើមរុលសំរុកចុះមកក្រោមទៀត ដើម្បីមកដល់ទល់ដែនដៃ កម្ពុជាក្រោមនៃអ្នក ៗ ដែនដីដីមានជីជាតិ សម្បូណ៌ទៅដោយ ធនធានខាងកសិកម្ម មានស្រូវត្រី និងផលាក្រប់បែបយ៉ាង នៅដែនដីសណ្ត (Delta) នៃទន្លេមេគង្គ. និងបណ្តាជន ជាតិខ្មែរដែលមានចំនួនតិចនៅឡើយ (តាមស្ថិតិ ដែលមាន នាចុងសតវត្សទី ១៧ មានជនជាតិខ្មែរប្រហែល ៤០.០០០ គ្រួសារ គឺប្រហែល ២០០ ០០០ នាក់តែប៉ុណ្ណោះ នៅផ្នែក ជាង

...០០០ ឆ ម ២ ) (១) ហេតុដូច្នេះឯង បានទាក់ទាញ ការឃ្លាំង ដល់អាណានិគម យួនជាខ្លាំង ដែលជាច្រើន សតវត្សមកហើយ បានឃ្លាតកាន់តែឆ្ងាយទៅពីតំបន់ដីសណ្ដរ នៃទន្លេក្រហម ( Delta du Fleuve Rouge ) ជាភូមិភាគ កំណើតរបស់ខ្លួន ប្រកបដោយផលផលិតកសិកម្ម ដូចជាដែន ដីសណ្ដរទន្លេមេគង្គដែរ ។

ការស្វែងរកនេះហើយ គោលបំណងយកភូមិភាគខាង ត្បូង នៃកម្ពុជា ត្រូវបានជាគោលការណ៍ដែលត្រូវអនុវត្តភ្លាម ។ នៃជនជាតិវៀតណាម ចាប់តាំងពីសតវត្សទី ១៧ មកម្ល៉េះ ។ តាំងពីដើមសតវត្សទី ១៧ គេក៏ចាប់ផ្ដើមចូលមកតាំងនៅ ដោយ ស្ងៀមស្ងាត់ជាធម្មតា ក្នុងចំណោមតំណាខេត្តខ្មែរ ដែលខាង កើតនៃដែនដី កម្ពុជាក្រោម គឺភូមិភាគ បារៀ ( Baria ) បៀន ហ្វា ( Bien Hoa ), ព្រៃនគរ សព្វថ្ងៃនេះ ។ ការតាំងទី

(១)យោងតាមសៀវភៅរបស់ Lê Thành Khôi, Le Viet-Nam, Éditions de Minuit, Paris, 1955.



នេះធ្វើបាន គឺដោយសារតែការហូរចូលច្រើនហួស នៃជន ការខ្មែរយើង ក្នុងខេត្តទាំងឡាយនោះ , ហើយការស្វែង យ៉ាងទៀត មកអំពីសង្គ្រាមក្នុងស្រុករវាងគ្នាឯង ក្នុងការកែង ដណ្ដើមបល្ល័ង្កគ្នានៃក្សត្រខ្មែរ ។ ក្នុងឆ្នាំ ១៦៧១ ជនជាតិ ខ្មែរបានទៅសូមជំនួយពីស្ដេច ហៀង វឿង ( Hien Vuong ) ដើម្បីទប់ទល់នឹងក្សត្រដណ្ដើមរាជ្យមួយអង្គ ។ ហៀង វឿង ក៏ ប្រញាប់ប្រញាល់បញ្ជូនកងទ័ព មួយពលធំទៅជួយ ហើយ ទៀតទុកាសនោះធ្វើការបន្ថែ ដណ្ដើមយកអាណាខេត្តបារៀ និងបៀនហ្វាបន្ថែមទៅ ទុកជាសគុណ នៃជំនួយនោះ ។ នយោបាយអន្តោប្រវេសន៍ទៅក្នុងនៃជនជាតិយួន នេះតែមានបន្ត ទៅទៀតស្របតាមបណ្ដាលដែលមានញយ ។ ក្នុងប្រទេស កម្ពុជា ។ ហេតុនេះហើយ ក្នុងឆ្នាំ ១៦៩៦ អាណាខេត្តព្រៃ នគរ ក៏ត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃជនជាតិយួន ហើយមក ដល់ដើមសតវត្សទី ១៨ ការកាន់កាប់តំបន់នេះ បានមកដល់ទន្លេ មេគង្គជាស្រេច ។ នាដើមសតវត្សទី ១៨ ដោយសំគាន់

ទៅលើកិច្ចការពាររបស់ខ្លួន ប្រឆាំង នឹងសៀម ទៅលើឈ ណាៈខេត្តខ្លះផ្នែកខាងលិច នៃកម្ពុជាក្រោម ខេត្តពាម ( Ha Tien ) រាជា ( Rach gia ) សព្វថ្ងៃនេះ ជនជាតិយួន កំ មកធ្វើកន្លុកតបន៍ថ្មីទៀត ទៅលើខេត្តទាំងនោះ ។ ឆ្នាំ ១៧៣៩ ព្រះបរមហាក្សត្រខ្មែរទ្រង់បានធ្វើសង្គ្រាម យកខេត្តពាមមកវិញ តែពុំបានសម្រេចដូចបំណង ។ តពីនេះទៅ ពពួកខេត្ត ផ្នែកកណ្ដាល នៃកម្ពុជាក្រោម មានខេត្ត មេស (My tho) វិញឡុង (Vinh long) ( ១៧៣២ ) ផ្សារដែក ( Sa Dec) និង មាត់ជ្រូក ( Chau Doc ) ( ១៧៥៧ ) ក៏របេះពីមាតុ ភូមិខ្មែរម្ដងមួយ ៗ ធ្លាក់ទៅក្នុងកណ្ដាប់ដៃ នៃជនជាតិយួន , អាណានិគមស្រែចំការដី ថ្មីៗបើមានការតក់ និង កសិកម្មពីព មកស៊ីក្រុងក្រុងក៏កើតឡើយ ៗ នាឆ្នាំ ១៧៦៨ ដែលដីកម្ពុជា ក្រោមទាំងមូល ធ្លាក់ទៅជាដែនដីអាណានិគមយួន លើក លែងតែខេត្តត្រាំង ( Soc trang ) និង ជ្រោយទឹកខ្មៅ (Camau) ដែលទាល់តែជិតមួយសតវត្សទៀត គឺឆ្នាំ ១៨៤០



ទើបធ្លាក់ទៅក្នុងអំណាចយួនជាដាច់ស្រេច ។

... គឺពេលនោះមក ប្រវត្តិសាស្ត្រនៃ កម្ពុជាក្រោម ដូចជា ប្រវត្តិសាស្ត្រនៃ នគរចម្ប៉ា ដែរ គឺរលាយចូលជាមួយនឹងប្រវត្តិសាស្ត្រនៃប្រជាជាតិវៀតណាមរហូតមកទល់ថ្ងៃនេះ ។

x

x x

## អាណានិគមនិយមបារាំង ៣ ប៉ះទង្គិចគ្នា នៅឥណ្ឌូចិន

ការដែលយើងយកគតិកាលដ៏ខ្លីនេះ មកព្យាករណ៍ពី នេះដើម្បីនឹងគោលបំណងមួយច្បាស់លាស់ណាស់ គឺដើម្បី ចង្អុលការវិវត្តន៍នៃប្រវត្តិសាស្ត្រក្នុងកាល នៃពិភពលោក នេះវិចិត្រណ្ណៈ គ្រាន់ជាគន្លឹះដល់សម្បជញ្ញៈ នៃយើងរាល់ គ្នា ។ ការនិទ្ទេសឲ្យគិតប្លែកទាក់ទាស ទៅលើជនណាម្នាក់ ប្រព្រឹត្តកំណាមួយឬផ្ទុយទៅវិញ ការសរសេរសារគ្គី ឬ ការញ៉ាំង ឲ្យមានការស្អប់ខ្ពើម ទៅនឹងជាតិមួយនិងជាតិមួយទៀត . . តាំង គស់នេះមិនមែនជាគោលដៅនៃប្រវត្តិវិទូទេ ។ ផ្ទុយនេះការ រៀបជាការចាំបាច់ ខាងផ្លូវបញ្ញា ( Besoins de l'intelligence) ដើម្បីកន្សាលវិចិត្រណ្ណៈ ។



តាំងពីដើមរៀងមក អាណានិគមនិយមនិងការគ្រើកចិត្ត ជាតិនិយម នៃ សៀម ហើយនិង យួន ជាការគំរាមកំហែងដ៏ គ្រោះ ថ្នាក់បំផុតដល់អាយុជីវិតនៃប្រទេស កម្ពុជា និង លាវ ។ មុន ការមកដល់ នៃជនជាតិស្បែកស ក្នុងភូមិភាគនេះ នៅដើម សតវត្សទី ១៩ កម្ពុជា និង លាវ សឹងតែស្លាប់ខ្លួនរលាយអស់ក៏ត្រូវ នៃចបញ្ញានិងប្រទេសដ៏ច្រើនទៀតនៃពិភពលោកនៅហើយៗ កែ ពេលនោះប្រវត្តិសាស្ត្រធ្លាក់ជួបជាដើររឿង, ស្របទៅតាម រឿង នៃប្រវត្តិសាស្ត្រ និងបច្ចេកទេសនៃបញ្ចាំមប្រទេស ។

ក្នុងរជ្ជព្រះបាទ មិញ ម៉ាង ( Minh Mang) (១៨២០ –១៨៤១ ) ប្រទេសកម្ពុជា តាំងមួយត្រូវបែងចែកជាកាត ដែលមានខេត្តនៃវៀតណាមគ្រប់គ្រងត្រាក់ទណ្ឌនៃក្រុមពាណិជ្ជកោតិនិង បាត់ដំបង ហើយនៅឡើងនេះចូលបីនិងខេត្តសាបទៀបទៅដល់ម្ចាស់ក្រ មុខនឹងការប្រជើងផ្ទោះទៅសួរគ្រងទៅដល់ព្រំ ប្រទេសថៃ–វៀត ណាមសព្វថ្ងៃនេះ ។ ផ្ទុយនេះដើម្បីមួយភាគបីនៃកម្ពុជាភាគខាង ជើងខេត្តសាបក្លាយទៅជាអាណានិគមសៀម ។ ២ភាគ៣

នៃដែនដីខ្មែរក្រោមខ្សែបន្ទាត់ ដែលនោះក្លាយទៅជាអាណា-
ខេត្តយួនឈ្មោះ ត្រាន តាយ ថាញ់ ( Trân Tay Thanh )
ដែលមានមេទ័ព ត្រឿង មិញ យ៉ាង ( Trung Minh Giang )
ជាស្តេចត្រាញ់មានធានីនៅ ណាំយ៉ាង (ភ្នំពេញ) ។

នេះក្រោកដែរ ដំណើរឡើងមកទិសខាងលិច វិញដោយ
ហេតុ ដំណើរសំរុកចុះមកក្រោម បានសម្រេចដល់គោលដៅ
ក្រោយក្រោយ ទឹកខ្មៅ ( Camau ) ជាដែនដីខាងត្បូងបំផុតនៃ
កម្ពុជា បានត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃយួនរួចទៅហើយ ។
តែអាណាខេត្តត្រាន តាយ ថាញ់ នេះពុំមានអាយុយឺនយូរទេ
ព្រោះការអនុវត្តន៍នយោបាយគំនិតខុស បញ្ចូលខ្មែរឲ្យទៅជា
យួន (politique d'assimilation forcée) បណ្តាលឲ្យមានប្រតិ
កម្មយ៉ាងខ្លាំងពីសំណាក់មហាជនខ្មែរ ។ ការបះបោរប្រឆាំងបំ
បាត់យួនជះជាន់ដឹកនាំដោយ .. ព្រះអង្គឡុង ដោយមានជំនួយ
សៀមផង បានធ្វើឲ្យអំណាចយួនមានការខ្វះខាតយ៉ាងច្រើន



ហើយ ត្រឿង មិញ យ៉ាង ក៏ដកខ្លួនថយទៅនៅ អាន យ៉ាង
( Ang Giang ) ក្នុងឆ្នាំ១៨៤១ ។ នយោបាយធ្វើខ្មែរឲ្យទៅ
ជា យួន ក៏ត្រូវទទួលបរាជ័យយ៉ាងជាក់ស្តែង ។ ជាមួយគ្នា
នេះ ការមកដល់នៃពួកបារាំងតាំងពីឆ្នាំ ១៨៥៨ ទៅ នៅ
ដែនដីកូសាំងស៊ីនបានបើកយុគថ្មីមួយទៀត ក្នុងប្រវត្តិសាស្ត្រ
នៃកម្ពុជា ។ អាណានិគមនិយមយួន ក៏ត្រូវឈប់ស្ទះ
មួយអន្លើសិន ....., ព្រោះប្រទេសយួនខ្លួនឯង ត្រូវ
ក្លាយទៅជាដែនដីអាណានិគមបារាំងវិញ ។

ចំណែកឯគូបដិបក្ខសៀមនៃកម្ពុជាមានបារាំងជំនួស សៀម
កាប ម្លៃព្រៃ ខេត្តបាត់ដំបងនិងសៀមរាប សៀមត្រូវរក្សាទុក
ដល់ឆ្នាំ១៩០៧ ទើបប្រគល់មកឲ្យខ្មែរវិញ ដោយសារការ
សន្តិភាពសន្ធិសញ្ញាទូតនឹងផ្លាស់ប្ដូរនយោបាយ នៃប្រទេសបារាំងអា-
ណានិគមនិយម ដែលប្ដូរដែនដីទាំងនោះ ជាមួយនឹងខេត្ត
ត្រាត និងចន្ទបុរី ជាអាណាខេត្តសៀម ទល់មុខនឹងខេត្ត
កោះកុងបច្ចុប្បន្ននេះ ។

ចំពោះឯណាវិញ ក៏ស្ថានការណ៍មិនខុសពីកម្ពុជាដែរ ពីព្រំដែនចិនមកដល់ខ្មែរ ប្រទេសលាវត្រូវបែងចែកតាំងពីដើម សតវត្សទី ១៩ ទៅជាអាណាខេត្តសៀម និង យួន ហើយ នៅសល់តែរាជាណាចក្រតូច នៃ ហ្លួងព្រះបាង និង ចំប៉ាសាក់ ដែលនៅរដ្ឋចាំ ការបែងចែកបន្តទៅទៀតប៉ុណ្ណោះ ។ ក៏ ប៉ុន្តែដូច កម្ពុជា ដែរ ការយកផលនៃអាណានិគមនិយមបារាំង បានស្រោចស្រង់ លាវ ឲ្យផុតភ័យមហន្តរាយ . . . ។

នេះជាការពិត , អាណានិគមនិយមបារាំង គឺជា ហ្វ្រាំងដ៏សក្តិសិទ្ធិ ទប់អាណានិគមនិយម ពង្រីកទឹកដីសៀម និងយួននៅសតវត្សទី ១៩ មិនឲ្យលេបដែនដីខ្មែរ និងលាវ តទៅទៀតបាន ។

x

x x

# ឯណាគ្រោះថ្នាក់ ?

តើគ្រោះថ្នាក់យើងនៅឯណា ? យួនឬសៀម ? តើ ប្រទេសសៀម ជាមហាគ្រោះថ្នាក់ដល់អនាគតនៃ កម្ពុជា មែន ឬ ? ប្រទេសសៀមសម័យបច្ចុប្បន្ននេះ ជាប្រជាជាតិមួយ ធំ ( ជាង ៣០ លាននាក់ ) ដែលមានទីតាំង នៅកណ្ដាល នៃឧបទ្វីបអាស៊ីអាគ្នេយ៍ដីគោក លើដែនដីមួយ ដែលមាន ទន្លេមេណាម (= មេទឹក) ហូរកាត់ជាកណ្ដាល ហើយដែល ប្រកបទៅដោយដីជាតិ ហើយ និង ធនធានកសិកម្មយ៉ាងធំ ធេង ។ ទីតាំងនៅកណ្ដាលយ៉ាងនេះ នៃប្រទេសសៀម លើវាលទំនាបស្តុកស្តម្ភ ( au milieu d'une plaineriche ) បានផ្តល់ឲ្យប្រទេសសៀមនូវ នាទីមួយយ៉ាងធំ ក្នុងភូមិភាគនេះ នៃពិភពលោក ។ តែការពិត ហាក់ដូចមិនដូច្នេះសោះ ។

ប្រទេសសៀមមានលក្ខណៈជាដែនដីមួយ ដែលមានការលាតសន្ធឹងជាអតិបរមា ទៅហើយ ពីខាងជើង គឺទល់ដែនសៀម លាវ – ភូមា មកដល់ខាងត្បូងទល់ដែនសៀម –ម៉ាឡេស៊ី មានបណ្ដោយ ប្រហែលពីរពាន់គីឡូម៉ែត្រ ហើយប្រទេសនេះក៏ខ្វះឯកភាពភូមិសាស្ត្រ(absence de l' unité géographique) នយោបាយ និងសេដ្ឋកិច្ចផង ។ ភូមិភាគប្រកបដោយផលដំណាំដីសណ្ដរ នៃទន្លេមេណាម ដែលមានបណ្ដោយ ប្រហែល ៤៦០ គម និងទទឹង ៦០០ គម ។ ដីនេះ គឺជាជង្រុកស្រូវ នៃប្រទេសសៀម , ជាបេះដូងសេដ្ឋកិច្ចជាតិ ។

ភូមិភាគផ្សេងពីនេះ ជាភូមិភាគបន្ទាប់បន្សំ ចំពោះជនជាតិសៀម ហើយអ្នកដែលរស់នៅទីនោះមិនមែនជា ជនជាតិសៀមសុទ្ធសាធផង៖ ពីចុងខាងជើងគឺពួកជនជាតិភាគតិច ការេន, ចាម, លាវ ខាងជើងទៀតខាងកើតគឺ លាវ និង ខ្មែរ ខាងត្បូងទៀតខាងកើតគឺខ្មែរ ហើយនិងចិន ឯខាងត្បូងមានជនជាតិម៉ាឡាយូ កាន់សាសនាឥស្លាម ។ ជនជាតិបរទេសទាំង



នេះដែលរស់នៅជុំវិញទន្លេមេណាម មានការកាត់អន់ចិត្តជាខ្លាំងដោយជនជាតិសៀមទុកពួកទាំងនេះ ជា «ពលរដ្ឋបន្ទាប់បន្សំ( Citoyens de seconde zone ) ហើយការលូតលាស់ខាងសេដ្ឋកិច្ចទៀតសោត ក៏យឺតយូរដោយពេកជាច្រើន បើប្រៀបធៀបនឹងភូមិភាគក្រុងបាងកក និងតាមដែនទន្លេមេណាម ដែលជនជាតិសៀមនិងចិនរស់នៅដោយកកកុញ ។ ហេតុការណ៍ទាំងនេះបណ្ដាលឲ្យមានចលនាអ្នកជាតិនិយម (Mouvement séparatistes ) នៅតាមដែនដីទាំងនោះ ជាគ្រោះថ្នាក់មួយយ៉ាងធំចំពោះឯកភាពខាងនយោបាយនៃប្រទេស ។

បញ្ហាធំ ដែលនៅសព្វថ្ងៃ គឺការកើនជនឆាប់រហ័ស (une démographie galopante) នៃជនជាតិសៀម ។ ដែនដីសណ្ដរនៃទន្លេមេណាមនឹងពុំអាចទប់ទល់ដល់ទម្ងន់ ពីកាន់តែច្រើនឡើងៗនោះទេ ។ ដូច្នេះដើម្បីដោះស្រាយបញ្ហានេះ គេត្រូវតែជ្រើសគន្លងនានាសកម្ម ឯដីដែលនៅជុំវិញ ដែលដីសណ្ឋានក្រទាំងអស់ ។ នេះហើយដែលធ្វើជនជាតិ

សៀវភៅគិតទៅដល់ ទីកន្លែងនាបនៃទស្សនវិជ្ជានិងទស្ស
នាបបាននៃក្រុមគ្រប់ជំរើសខ្វាជាដើម ដែលសម្បូរទៅដោយ
ពពួកពាលកសិកម្ម គាប់ចិញ្ចឹមមនុស្សច្រើនលាននាក់ ។ ប៉ុ
ន្តែសម័យបច្ចុប្បន្ននេះ គម្រោងផែនការនេះ ហាក់ដូចមិនទាន់
បានសម្រេច ដោយហេតុថា សៀមមានបញ្ហាផ្សេងៗ . . .
ក៏ប៉ុន្តែទៅអនាគតទៅ បើសេដ្ឋកិច្ចសៀមមិនបានល្អគួរសម
ឲ្យស្របទៅតាមការកើនយ៉ាងរហ័សនៃបណ្ដាជនទេ ការវាយ
ដណ្ដើមយកដីខាងលិចនៃប្រទេសកម្ពុជា គាប់ទៅជាការកើត
បាន ។

នេះស្របទៅលើការវិវឌ្ឍន៍នៃប្រវត្តិសាស្ត្រ ។ គឺ
បច្ចុប្បន្ននេះសៀមនៅខ្វះខ្សោយខាងផ្សេងៗ កុំគាប់លាតសន្ធឹង
បានទៀតទេ បើមិនដូច្នោះទេឯកការសៀម ច្បាស់ជាត្រូវ
ទទួលការតក់ស្លុតពីជនជាតិការគិតយ៉ាងខ្លាំងមិនលែង
ឡើយ ។ ការលាតសន្ធឹងហួសមាត្រ គឺនាំមកឲ្យសៀមនូវ
ភាពទន់ខ្សោយវិញទេ ។ គឺស្រ័យហេតុនេះហើយ បើ



តាមយោបល់របស់យើង គ្រោះថ្នាក់របស់យើងមិនមែនទៅទិស
ខាងលិច គឺខាងកើតជាប្រាកដ ។

ប្រទេសវៀតណាមរួបរួមគ្នា . . . គ្រោះថ្នាក់
ដល់កម្ពុជា !

បើប្រទេសវៀតណាមខាងជើង និងខាងត្បូងរួបរួមគ្នា
វិញ ប្រទេសនេះ នឹងទៅជាប្រទេសជាកំលាំងធំនៃតំបន់អា
គ្នេយ៍ (៤០លាននាក់) ។

បើប្រទេសណាជាចំនួនបណ្ដាជនជាកត្តាមួយ បន្ទាប់
បន្សំនៃមហិទ្ធិរឹទ្ធិនយោបាយ ( la puissance politique )
នៃរដ្ឋនីមួយៗ គុណសម្បត្តិនៃប្រជាការស្ត្រ (les qualités d'un
peuple )និងការវិវឌ្ឍន៍នៃបណ្ដាជន (L'évolution de la po-
pulation ) ប្រាកដជាកត្តាដែលសំខាន់ជាងគេបំផុត ។
ចំណែកឯកត្តាទាំងពារនេះ ជនជាតិវៀតណាមមានទាំងអស់
ដោយឥតប្រកែកបាន –ទី១ បណ្ដាជនច្រើនគាប់លេបត្រួ
ពិនទៅអនាគតបាន, ទី២ការកើនដ៏លឿនរហ័សនៃបណ្ដាជន

នេះ, និងទីញសំខាន់បំផុតគឺគុណសម្បត្តិជាពិសេស នៃប្រជារាស្ត្រវៀតណាមនេះឯង ។ ចំពោះករណីខាងក្រោយនេះ បើមានផលជាតិឯណា ដែលគេអាចយកទៅប្រដូចបាន ជាមួយនឹងផលជាតិយួនគឺផលជាតិចុំនឹងកាល្បីម៉ឺននេះឯង ។ ផលជាតិយៀកណាម ជាប្រជារាស្ត្រមួយប្រកប,ដោយក្រាញ់ថាមពល សេចក្តីក្លាហាននិងពិសេសបំផុតចិត្តតស៊ូ ។ ល ។ ប្រវត្តិសាស្ត្រនៃជនជាតិយៀកណាមនេះ ជាប្រវត្តិសាស្ត្រនៃសង្គ្រាមដែលប្រជារាស្ត្រយៀកណាមបានធ្វើ ដោយឥតស្រាកស្រាន្តជាមួយនឹងបរទេស នៅពីគខាងជើង ចិនចម្ប៉ា ណាំ សៀម ខ្មែរនិងកេងក្លានិងក្លាខាងជើងចល់និងខាងត្បូង ។ ការនេះកើតមានឡើង ជាច្រើនសតវត្សមកហើយ ហើយបាក់ឆ្អឹងជាគ្នាសញ្ញាឯណាបញ្ជាក់ថា សង្គ្រាមនេះនឹងឈប់ស្ងួរហើយ ពោះថាក្រោយការបញ្ចប់សង្គ្រាមនៅយៀកណាមសព្វថ្ងៃនេះក្តី ។ ភាសានៃប្រទេសយៀកណាមជាភាសានៃប្រជាជាតិមួយដែលពង្រីកទឹកដីដោយសង្គ្រាមហើយ ដែលត្រូវគេធ្វើសង្គ្រាមទៅអនាគតទៀត ។ សង្គ្រាមញឹកញយយ៉ាងនេះ បានសម្រេចធ្វើឲ្យជនជាតិយៀក



ណាមមានចរិតរឹងប៉ឹង ចេះអត់ធ្មត់សេចក្តីលំបាក មានការតស៊ូដោយស្វិតស្វាញ គឺលក្ខណៈទាំងនេះឯងហើយ ដែលជាការអនុគ្រោះដល់ការប្រយុទ្ធដោយវិធីហិង្សា ។ នេះជាកត្តាខាងផ្លូវចិត្តសាស្ត្រ ដែលសារសំខាន់ ចំពោះការយល់របស់យើង ។

ចូរយើងនឹកគិតទៅដល់ប្រវត្តិសាស្ត្រ ។ តើជនប្រភេទណាដែលមកកតទីតាំង នៅចម្ប៉ានិងនៅ កម្ពុជាក្រោម ? គឺជនអនាថាក្រលំបាកគោកយ៉ាក អ្នកទោសដែលគេបញ្ជូន គឺដែលខាងលើ ឲ្យចុះមកកេងទីតាំងដីថ្មី នៅភូមិភាគខាងក្រោម អ្នកទាំងនេះមកជាទាហានផង ជាអាណានិគមជន (Colons )ផង ។

មុនដំបូងមកតាំងនៅដោយស្ងៀមស្ងាត់ រួចហើយក៏តាំងបង្ករឿងហេតុពាល់ផ្លាស់ដីផុតខ្លួនចេញពីទីនោះទៅ ..។ ឥឡូវនេះព្រឹត្តិការណ៍នេះបាប់មានជាថ្មីឡើងវិញហើយ សព្វថ្ងៃនេះនៅកម្ពុជាយើង , យ៉ាងនេះគួរតែយើងមានបុព្វហេតុ នៃសេចក្តីបារម្ភរបស់យើង[១] ។

១_ក្នុងពេលនេះសរសេរក្នុងឆ្នាំ១៩៦៩ គឺមុនអន្តរាគមន៍នៃកងទ័ពយៀកណាមខាងត្បូងក្នុងប្រទេសកម្ពុជាក្រោយថ្ងៃទី១៨មីនា១៩៧០

## អាណានិគមនិយមពង្រីកដី
## ឬ អាណានិគមនិយមសេដ្ឋកិច្ច

(Colonialisme territorial ou Colonialisme économique?)

ការឈ្លានពានដណ្ដើមយកទឹកដី ដោយកម្លាំងទ័ព ក្នុងសម័យសតវត្សទី ២០ នេះ ហាក់ដូចជាហួសសម័យនិយមទៅហើយ ។ ដោយបច្ចុប្បន្នកាលនេះ ស្ថាប័នជាច្រើន នៃមនុស្សជាតិ មានអង្គការសហប្រជាជាតិ, មតិសាធារណអន្តរជាតិ អង្គការការពារសន្តិភាព និងបណ្ដាសម្ពន្ធមិត្តផ្សេងៗ សុទ្ធសឹងតែជាកម្លាំងមានផ្ទុយចិត្ត ជាទប់ស្កាត់ការរំលោភដណ្ដើមយកទឹកដីដោយស្រួល ពីសំណាក់ជាតិមួយ ទៅលើជាតិមួយទៀត ។

ក៏ប៉ុន្តែអាណានិគមនិយមសម័យថ្មី ដែលយើងគួរបារម្ភ



គឺអាណានិគមនិយមតាមរយៈសេដ្ឋកិច្ច ។ វៀតណាមខាងជើង ប្រកបដោយឧស្សាហកម្មដ៏ខ្លាំងក្លា និង វៀតណាមខាងត្បូងសម្បូរណ៍ធនធានកសិកម្ម កាលបំពេញគ្នាទៅវិញទៅមក ហើយក្លាយទៅជាសេដ្ឋកិច្ចមួយ លូតលាស់យ៉ាងលឿន នៃអាស៊ីភាគអាគ្នេយ៍ ។ កាន់តែសម្បូណ៌ទៅដោយវត្ថុធាតុដើម ជាតិរ៉ែ និងថាមពល កាន់តែរីកលូតលាស់ នៃវិទ្យាសាស្ត្រ ផ្សារដ៏ធំធេង គុណសម្បត្តិរបស់កសិកម្ម ។ល។ ដែលគេសង្កេតឃើញនៅមានប្រទេសវៀតណាមសព្វថ្ងៃនេះ សុទ្ធសឹងជាកត្តា នៃការរីកលូតលាស់ នៃឧស្សាហកម្មជាតិ នៃប្រទេសនេះ ។ ថ្វីបើប៉ុន្មានឆ្នាំនេះ ប្រទេសវៀតណាមត្រូវខូចខាតខ្ទេចខ្ទីសឹងតែទាំងអស់ ខ្លួសង្គ្រាមណៈ គ្រប់បែបយ៉ាងក្តី សហរដ្ឋអាមេរិក បានចាកចេញពីវៀតណាមក្រោយ ដែលសង្គ្រាមបញ្ចប់ ហើយដោយទុកឲ្យប្រទេសនេះស្ថិតក្នុងស្ថានភាព [illegible] ទៀត ។ ស.រ.អ. ត្រូវតែជាស្ថាបនាវៀតណាមឡើងវិញ ដើម្បីលុបលាងខ្លួនចំពោះ

ប្រវត្តិសាស្ត្រមនុស្សជាតិ ។ ដូច្នេះហើយ សេដ្ឋកិច្ចវៀតណាមមុខជាលេបសេដ្ឋកិច្ច នៃប្រទេសជិត ៗ ពិតជានឹងមិនលែងឡើយ ។ នេះជាជំហានទៅកាន់ការបាត់បង់ នូវឯករាជ្យនៃយើង ។

គឺពេលនេះហើយ ដែលប្រវត្តិសាស្ត្រ នឹងវិនិច្ឆ័យ "ដំណើរឆ្ពោះមកកាន់ទិសខាងលិច" នៃប្រជារាស្ត្រវៀតណាម ជាតិប្រាកដ ។

x

x x

# នយោបាយ «មហាប្រទេសវៀតណាម» ?

**La politique du Grand Vietnam ?**

យើងកុំហ៊ានសន្និដ្ឋានអ្វីទុកជាមុន ឲ្យប្រាកដប្រជា នឹងសាបយកជាក្បួនត្រឹមត្រូវ ចំពោះអនាគត នៃវាសនាជាតិយើង នោះពិតមែនហើយ តែយើងត្រូវតែមានភារកិច្ច ពេញលេញក្នុងបញ្ហានេះ ដើម្បីទាញនូវមេរៀនខ្លះ ៗ ដែលប្រវត្តិសាស្ត្របានធ្លាប់ស្គាល់ មានការពិសោធន៍រួចមកហើយ ។ ឧទាហរណ៍ ដែលមានលក្ខណៈជាសារវន្តនោះ មិនខ្វះទេ ក្នុងប្រវត្តិសាស្ត្រ នៃពិភពលោកយើងតាំងសម័យអតីតកាលថ្មី ៗ នេះ ។ យើងនៅចាំយ៉ាងជាក់ស្តែង ក្នុងស្មារតីយើងម្នាក់ ៗ នៅឡើយថា ក្នុងសម័យមុនសង្គ្រាមលោកលើកទី ២ ប្រ